World Health Organization
Western Pacific Region

កម្ពុជា
របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ លេខ#៨១
របាយការណ៍គិតត្រឹមថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០២២ ម៉ោង១០:00នាទីព្រឹក

## ស្ថានការណ៍សង្ខេបសំខាន់ៗ (ថ្ងៃទី៧ ដល់ថ្ងៃ ២០កុម្ភៈ ឆ្នាំ២០២២)

- ករណីវិជ្ជមានវីរុសកូវីដ-១៩ សរុបចំនួន ៥.០៩៦ និងករណីស្លាប់ដោយសារជំងឺកូវីដ-១៩ចំនួន៥ ត្រូវបានរាយការណ៍នៅក្នុងរយៈពេល ១៤ថ្ងៃចុងក្រោយនេះ។ ក្នុងចំណោម ៥.០៩៦ ករណីនោះ ៤ភាគរយជាករណីនាំចូល។ កម្ពុជាកំពុងមានករណីឆ្លងជំងឺកូវីដ-១៩កើនឡើងជាគំហុក និងមានការឆ្លងក្នុងសហគមន៍ទូលំទូលាយនៅរាជធានីភ្នំពេញ។
- ករណីសរុបទាំងអស់ចំនួន ១២៦.៩៧៧ ត្រូវបានបញ្ជាក់ថាជាករណីវិជ្ជមានវីរុសកូវីដ-១៩ និងករណីស្លាប់ចំនួន ៣.០២០ ត្រូវបានរាយការណ៍ដោយរាជរដ្ឋាភិបាលកម្ពុជា។ ក្នុងចំណោមនោះ ១២០.៧៦៧ ករណីបានជាសះស្បើយ។
- គិតត្រឹមថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២២ តេស្តសរុបចំនួន ២.៥៥២.១៨០ ត្រូវបានធ្វើដោយប្រើម៉ាស៊ីនតេស្តមន្ទីរពិសោធន៍ (RT-PCR)។ គិតចាប់តាំងពីខែមករា ឆ្នាំ ២០២០មក បុគ្គលសរុបចំនួន ១.៨២៦.១៨១ នាក់ បានធ្វើតេស្តរកវីរុសកូវីដ-១៩ ដោយប្រើបច្ចេកវិទ្យាធ្វើតេស្តប្រើម៉ាស៊ីននៅមន្ទីរពិសោធន៍ (Reverse-Transcriptase Polymerase Chain Reaction, RT-PCR) ដោយមានអត្រាវិជ្ជមានក្នុងកម្រិត ៥.០ ភាគរយ។
- ជារួម កម្ពុជាកំពុងមានករណីឆ្លងកើនឡើងជាគំហុកដោយសារចរចររបស់មេរោគកូវីដ-១៩បំប្លែងថ្មីអូមីក្រុងនៅក្នុងសហគមន៍ដោយមានការឆ្លងជាចង្កោមនៅតាមទីកន្លែងមួយចំនួនដូចជាតាមសាលារៀន កន្លែងធ្វើការ និងកន្លែងកម្សាន្ត។ ទោះបីជាមានកើនឡើងនូវករណីឆ្លង និងករណីស្លាប់ សមត្ថភាពថែទាំសុខភាពនៅមានស្ថេរភាពនៅឡើយទោះជាមានសញ្ញាដំបូងខ្លះបង្ហាញថាមានចំនួនអ្នកជំងឺស្នាក់នៅមន្ទីរពេទ្យកើនឡើង។ ការកែតម្រូវវិធានការសុខភាពសាធារណៈ និងសង្គមដើម្បីទប់ស្កាត់កុំឱ្យមានការចម្លងទ្រង់ទ្រាយធំ ការពង្រឹងការផ្តល់សេវាសុខភាព និងពន្លឿនការចាក់វ៉ាក់សាំងនៅតែជាផ្នែកអាទិភាព។

## ការរកឃើញបានឆាប់ និងឆ្លើយតបចំគោលដៅ

- **ការតាមដានជំងឺ:**
  - អង្គការសុខភាពពិភពលោក បានផ្តល់ការគាំទ្រដល់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាលដើម្បីពិនិត្យកម្មវិធីតាមដានជំងឺដែលជាផ្នែកមួយនៃផែនការការងារថ្នាក់ជាតិឡើងវិញ និងកំណត់អាទិភាពសម្រាប់ឆ្នាំ២០២២ រួមទាំងការពិនិត្យនូវប្រព័ន្ធតាមដានជំងឺផ្តាសាយឡើងវិញ។
  - អង្គការសុខភាពពិភពលោក កំពុងផ្តល់ការគាំទ្រដល់ក្រសួងសុខាភិបាលនៅក្នុងការវាយតម្លៃការប្រើតេស្តរហ័ស ការតាមដានជំងឺ និងការកែតម្រូវវិធានការសុខភាពសាធារណៈ និងសង្គមឡើងវិញ។
  - អង្គការសុខភាពពិភពលោក កំពុងផ្តល់ការប្រឹក្សាផ្នែកបច្ចេកទេសដល់ការបង្កើតប្រព័ន្ធតាមដានលំដាប់ហ្សែនវិភាគរកប្រភេទនៃមេរោគបំប្លែងថ្មី។
  - បានពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់បណ្តាខេត្តប្រើដើម្បីតាមដានជំងឺដោយប្រើព័ត៌មានច្រើនប្រភព។
  - កំពុងជួយពិនិត្យឡើងវិញនូវគោលការណែនាំរបស់ក្រសួងសុខាភិបាលស្តីពីការស្វែងរកអ្នកប៉ះពាល់ និងការធ្វើចត្តាឡីស័ក។

- **មន្ទីរពិសោធន៍:**
  - ជាផ្នែកមួយនៃវិធានការសាកលដើម្បីធានានូវការបន្តផ្តល់លទ្ធផលតេស្តគួរឱ្យទុកចិត្តបានដោយរដ្ឋជាសមាជិក អង្គការសុខភាពពិភពលោកកំពុងរៀបចំផ្ញើសំណាកទៅមន្ទីរពិសោធន៍ចំនួនបីនៅកម្ពុជា សម្រាប់ធ្វើតេស្តមេរោគកូវីដ-១៩ ដើម្បីវាយតម្លៃគុណភាពខាងក្រៅជុំទីពីរ។

## វិធានការសុខភាពសាធារណៈ និងសង្គម

- កាលពីថ្ងៃទី ៩ ខែកុម្ភៈ សម្តេចតេជោនាយករដ្ឋមន្ត្រី បានអំពាវនាវឱ្យមានការកាត់បន្ថយជួបជុំ និងពិធីកម្សាន្តសប្បាយ ក៏ដូចជាបន្តប្រុងប្រយ័ត្ន និងការពារពីការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសមេរោគបំប្លែងថ្មីអូមីក្រុងដែលកំពុងតែចរាចរយ៉ាងសកម្មនៅក្នុងរាជធានីភ្នំពេញ។ សម្តេច បានជម្រុញឱ្យទីតាំងនានាពង្រឹងការអនុវត្តវិធានការ ៣កុំ និង៣ការពារ និងអំពាវនាវឱ្យទៅចាក់វ៉ាក់សាំងដូសមូលដ្ឋាន និងដូសទីបី ឬដូសជម្រុញឱ្យបានគ្រប់ៗគ្នា។
- រាជរដ្ឋាភិបាលកម្ពុជាកាលពីថ្ងៃទី១៧ ខែកុម្ភៈ:បានចេញសារាចរណែនាំមួយណែនាំឱ្យរដ្ឋបាលរាជធានី-ខេត្ត និងអាជ្ញាធរពាក់ព័ន្ធពង្រឹងការអនុវត្តវិធានការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលក្នុងសហគមន៍នៃមេរោគកូវីដ-១៩ ជាពិសេសមេរោគបំប្លែងថ្មីប្រភេទអូមីក្រុង។ សារាចរ ក៏បានលើកទឹកចិត្តដល់ប្រជាជនទូទៅ និងអ្នករៀបចំការជួបជុំមនុស្ស ឱ្យធ្វើការកាត់បន្ថយចំនួនអ្នកចូលរួមក្នុងកម្មវិធីនានាឱ្យនៅកម្រិតអប្បបរមាដើម្បីធានាបាននូវការអនុវត្តវិធានគម្លាតសុវត្ថិភាពបុគ្គល និងសង្គមនៅទីតាំងកម្មវិធីនីមួយៗ។
- កាលពីថ្ងៃទី ២០ ខែកុម្ភៈ ក្រសួងសុខាភិបាលបានចេញសេចក្តីណែនាំបន្ថែមស្តីពីការពង្រឹងការអនុវត្តវិធានការសុខាភិបាលក្នុងការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃមេរោគកូវីដ-១៩ ជាពិសេសអូមីក្រុងនៅក្នុងសហគមន៍ ជាពិសេសការធ្វើតេស្តរហ័ស ការដាក់



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្ន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

ខ្លួននៅដាច់ដោយឡែកធ្វើការព្យាបាល ការទំនាក់ទំនង និងផ្តល់ព័ត៌មានដល់អាជ្ញាធរ ហើយនិងការចូលរួមអនុវត្តវិធានការ ៣ការពារ និង៣កុំឱ្យបានខ្ជាប់ខ្ជួន ការចូលរួមពន្លឿនការចាក់វ៉ាក់សាំងកូវីដ-១៩ដូសជម្រុញ និងកំហិតការជួបជុំដែលមានមនុស្សច្រើនកុះករ។

- អង្គការសុខភាពពិភពលោក កំពុងផ្តល់ការគាំទ្រដល់ក្រសួងសុខាភិបាលក្នុងការជម្រុញឱ្យមានការចូលរួបរបស់វិស័យផ្សេងៗទៀត ក្រៅពីវិស័យសុខាភិបាល និងអនុវត្តប្រព័ន្ធត្រួតពិនិត្យការអនុវត្ត និងអនុលោមតាមវិធានការសុខភាពសាធារណៈ និងសង្គមជាពិសេសនៅកម្រិតថ្នាក់ក្រោមជាតិ។

## ការប្រាស្រ័យទាក់ទងអំពីហានិភ័យ និងការចូលរួមរបស់សហគមន៍

- អង្គការសុខភាពពិភពលោក ផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ក្រសួងសុខាភិបាលដើម្បីជម្រុញការអនុវត្តនូវវិធានការសុខភាពសាធារណៈ និងសង្គមដូចជាការពាក់ម៉ាស់នៅពេលចេញក្រៅ ការលាងសម្អាតដៃញឹកញាប់ជាមួយនឹងសាប៊ូ ការជៀសវាងកន្លែងជួបជុំ និងពិធីជួបជុំមនុស្សកុះករ និងទៅចាក់វ៉ាក់សាំងនៅពេលដល់វេនអ្នក ជាពិសេសផ្តោតទៅលើស្ត្រីមានផ្ទៃពោះនៅលើបណ្តាញផ្សព្វផ្សាយទូរទស្សន៍ វិទ្យុ និងបណ្តាញសង្គម។ ស្ប៉ត់វីដេអូ និងវិទ្យុ ត្រូវបានរៀបចំផលិតជាភាសាខ្មែរ។
- អង្គការសុខភាពពិភពលោកកំពុងធ្វើការជាមួយនឹងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល ដើម្បីធ្វើបង្កើយផែនការសម្រាប់យុទ្ធនាការជាតិផ្សព្វផ្សាយការយល់ដឹងដែលរំពឹងថានឹងចាប់ផ្តើមនាពាក់កណ្តាលខែមីនាឆ្នាំ២០២២នេះ ដើម្បីលើកកំពស់ និងជម្រុញឱ្យមានការចូលរួមពីបុគ្គល និងគ្រួសារក្នុងការធ្វើសេចក្តីសម្រេចចិត្តប្រចាំថ្ងៃបានត្រឹមត្រូវដើម្បីទប់ស្កាត់កុំឱ្យការចម្លងទ្រង់ទ្រាយធំនៅកម្ពុជា។
- អង្គការសុខភាពពិភពលោកដោយមានការគាំទ្រពីការិយាល័យថ្នាក់តំបន់ បានធ្វើយុទ្ធនាការអំពីការពិតនៃវ៉ាក់សាំងជាភាសាខ្មែរ តាមបណ្តាញហ្វេសប៊ុក ចាប់តាំងថ្ងៃទី ១០ ខែកុម្ភៈ និងបន្តដល់ថ្ងៃទី៩ ខែមីនា ដើម្បីបង្កើនការទទួលយកវ៉ាក់សាំងនៅក្នុងចំណោមប្រជាជនគោលដៅ។

## ការចាក់វ៉ាក់សាំងកូវីដ-១៩

- ការចាក់វ៉ាក់សាំងកូវីដ-១៩ដូសជម្រុញដោយប្រើវ៉ាក់សាំងប្រភេទ Sinovac សម្រាប់កុមារអាយុចាប់ពី ៦ឆ្នាំដល់អាយុក្រោម១២ឆ្នាំ និងកុមារអាយុ៥ឆ្នាំ នឹងចាប់ផ្តើមពីថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០២២តទៅ។
- ការចាក់វ៉ាក់សាំងកូវីដ-១៩ដូសមូលដ្ឋានដោយប្រើវ៉ាក់សាំងប្រភេទ Sinovac សម្រាប់កុមារអាយុចាប់ពី ៣ឆ្នាំដល់អាយុក្រោម៥ឆ្នាំ នឹងចាប់ផ្តើមពីថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០២២តទៅ។
- គ្រឿងបរិក្ខាប្រព័ន្ធត្រជាក់ខ្លាំង (ultra-low temperature, ULT: -90°C) ចំនួន៣៣គ្រឿងសម្រាប់រក្សាទុកវ៉ាក់សាំងPfizer និងគ្រឿងបរិក្ខាប្រព័ន្ធត្រជាក់ (-20°C) ចំនួន១០០គ្រឿងបានមកដល់កម្ពុជាកាលពីថ្ងៃទី ១៨ ខែកុម្ភៈ និងគ្រោងនឹងចែកចាយទៅតាមបណ្តាខេត្តក៏ដូចជាការិយាល័យស្រុកប្រតិបត្តិផងដែរ។
- វ៉ាក់សាំងប្រភេទ Pfizer ដែលជាបំណែងចែកពីអាស៊ានចំនួន១៣៩.០០០ដូស នឹងមកដល់កម្ពុជាសប្តាហ៍នេះ។ គិតត្រឹមថ្ងៃទី ២០ ខែកុម្ភៈឆ្នាំ២០២២នេះ រាជរដ្ឋាភិបាលកម្ពុជាទទួលបានវ៉ាក់សាំងកូវីដ-១៩ចំនួន ៤៣.៧៩២.៥៣០ ដូស ហើយវ៉ាក់សាំងកូវីដ-១៩ ចំនួន ៩.៦០៤.៤២២ ដូសនៅសល់ក្នុងស្តុក។
- ការគាំទ្ររបស់អង្គការសុខភាពពិភពលោកដល់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ៖
    - បានបង្ហើយផែនការសកម្មភាពសម្រាប់សកម្មភាពចាក់វ៉ាក់សាំងកូវីដ-១៩ចំនួន។
    - ការពិនិត្យឡើងវិញនូវផែនការជាតិដាក់ពង្រាយ និងចាក់ថ្នាំបង្ការសម្រាប់វ៉ាក់សាំងកូវីដ-១៩។
    - ការដាក់ពង្រាយវ៉ាក់សាំងកូវីដ-១៩។
    - ការវិភាគ និងរបាយការណ៍អំពីការចាក់វ៉ាក់សាំង និងទិន្នន័យអំពីហេតុការណ៍កើតឡើងក្រោយពេលចាក់វ៉ាក់សាំង រួមទាំងការចែករំលែកព័ត៌មានដល់ភាគីពាក់ព័ន្ធ។

## អន្តរាគមន៍ និងការផ្តល់សេវាសុខភាព

- កិច្ចពិភាក្សាករណីគ្លីនិកតាមប្រព័ន្ធអនឡាញមួយត្រូវបានរៀបកាលពីថ្ងៃទី ១៧ ខែកុម្ភៈដោយមានការចូលរួមពីមន្ទីរពេទ្យខេត្តមណ្ឌលគិរី។ វេទិការនេះផ្តល់ឱកាសដល់បុគ្គលិកថែទាំសុខភាពមកពីមន្ទីរពេទ្យថ្នាក់ក្រោមជាតិផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍ជាក់ស្តែងជាមួយនឹងក្រុមគ្រូពេទ្យ និងវេជ្ជៈបណ្ឌិតជួរមុខធ្វើការនៅមន្ទីរជាតិ ឬមណ្ឌលព្យាបាលជំងឺកូវីដ-១៩។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្ន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

- ការបង្ហាត់បង្ហាញផ្ទាល់ពីរបៀបព្យាបាលដោយប្រើអុកស៊ីសែន កំពុងត្រូវបានរៀបចំនៅមន្ទីរពេទ្យបង្អែកស្រុកចំនួន៤គឺ មន្ទីរពេទ្យបង្អែកអង្គរជុំ មន្ទីរពេទ្យបង្អែកក្រលាញ់ មន្ទីរពេទ្យបង្អែកពួក និងមន្ទីរពេទ្យបង្អែកសូទ្រនិគមនៃខេត្តសៀមរាបនៅសប្ដាហ៍នេះ។ យ៉ាងហោចណាស់ក៏បុគ្គលិកចំនួន១០នាក់មកពីមន្ទីរពេទ្យ ឬមណ្ឌលព្យាបាលកូវីដ-១៩ បានចូលរួមក្នុងការបង្ហាត់បង្ហាញដោយផ្ទាល់នេះ។
- កាលពីថ្ងៃទី១៣ ខែកុម្ភៈ ក្រសួងសុខាភិបាល បានចេញសេចក្ដីណែនាំស្ដីពីការពង្រឹងការអនុវត្តនីតិវិធីប្រតិបត្តិស្តង់ដារសម្រាប់ការគ្រប់គ្រង ថែទាំ និងព្យាបាលជំងឺកូវីដ-១៩នៅតាមផ្ទះ។ សេចក្ដីណែនាំនេះរួមបញ្ចូលការរក្សាអនាម័យស្អាតផ្ទាល់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ការប្រើឱសថសម្រាប់ការព្យាបាលអ្នកជំងឺកូវីដ-១៩កម្រិតស្រាល ឬគ្មានរោគសញ្ញាដោយត្រូវប្រើឱសថប្រឆាំងវីរុសដូចជាម៉ូលនូពីរ៉ាវា ការបញ្ចប់ការព្យាបាល និងការគ្រប់គ្រងកាកសំណល់របស់អ្នកជំងឺ។

## អេពីដេមីសាស្ត្រ

### ក្រាហ្វិកទី១. ខ្សែកោងអេពីដេមិកនៃករណីជំងឺកូវីដ-១៩ បញ្ជាក់ដោយមន្ទីរពិសោធន៍ បែងចែកតាមកាលបរិច្ឆេទនៃរបាយការណ៍ឆ្នាំ២០២១-២០២២*




*ចាប់ពីថ្ងៃ ៣០ ខែកញ្ញាឆ្នាំ២០២១មក មានតែលទ្ធផលតេស្តវីរុសកូវីដ-១៩ បញ្ជាក់ដោយ PCR ប៉ុណ្ណោះដែលត្រូវបានរាយការណ៍ជាចំនួនករណីឆ្លងផ្លូវការ

### តារាងទី១. តារាងសង្ខេបអំពីស្ថានភាពកូវីដ-១៩

| បច្ចុប្បន្នភាពអេពីដេមីសាស្ត្រអំពីកូវីដ-១៩ | ចំនួនតេស្ត | ករណីឈឺ | ករណីស្លាប់ | |
|---|---|---|---|---|
| | 39,106<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចក្នុងពេល១៤ថ្ងៃចុងក្រោយ | 5,096<br>ករណីវិជ្ជមានថ្មីក្នុងពេល១៤ថ្ងៃចុងក្រោយ | 5<br>ករណីស្លាប់ក្នុងពេល១៤ថ្ងៃចុងក្រោយ | 181<br>ករណីនាំចូលក្នុងពេល១៤ថ្ងៃចុងក្រោយ |
| | 2,552,180<br>ចំនួនតេស្តអាស៊ីតនុយក្លេអ៊ិចសរុប | 126,977<br>ករណីសរុប | 3,020<br>ករណីស្លាប់សរុប | |



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

**ការផ្តល់សេវាសុខភាពអំពីកូវីដ-១៩**

| 79 | 145 | 1,626 |
|---|---|---|
| ចំនួនមន្ទីរពេទ្យដែលទទួលព្យាបាលអ្នកជំងឺកូវីដ-១៩ | ចំនួនមណ្ឌលព្យាបាលអ្នកជំងឺកូវីដ-១៩ | ចំនួនគ្រែដែលមាននៅមន្ទីរពេទ្យ និង មណ្ឌលព្យាបាល |

ប្រភពទិន្នន័យ៖ រាជរដ្ឋាភិបាលកម្ពុជា យុទ្ធសាស្រ្តស្តីពីការរស់នៅតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩ (ថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ២០២១)

### តារាងទី២. ការវាយតម្លៃ[1]អំពីដំណាក់កាលចម្លងតាមខេត្តនីមួយៗ

| ដំណាក់កាលចម្លង | ខេត្ត |
|---|---|
| ដំណាក់កាលចម្លងទី៣: ការឆ្លងក្នុងសហគមន៍ទ្រង់ទ្រាយធំ | រាជធានីភ្នំពេញ |
| ដំណាក់កាលចម្លងទី២: ការឆ្លងក្នុងសហគមន៍តាមតំបន់ | ខេត្តព្រះសីហនុ ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពត ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង ខេត្តព្រះវិហារ ខេត្តស្វាយរៀង ខេត្តត្បូងឃ្មុំ ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ ខេត្តកោះកុង ខេត្តកែប ខេត្តក្រចេះ និងខេត្តប៉ៃលិន |
| ដំណាក់កាលចម្លងទី១: ករណីនាំចូល | ខេត្តពោធិសាត់ ខេត្តមណ្ឌលគិរី និងខេត្តរតនៈគិរី |

### តារាងទី៣. យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩តាមក្រុមគោលដៅ (បុគ្គលិកសុខាភិបាល មនុស្សចាស់ មនុស្សពេញវ័យ និងកុមារ)

| | បុគ្គលិកសុខាភិបាល | មនុស្សពេញវ័យ | | យុវវ័យ និងកុមារ | | |
|---|---|---|---|---|---|---|
| | | អាយុចាប់ពី ៦០ឆ្នាំ | អាយុចាប់ពី ១៨ឆ្នាំ | អាយុ៥ឆ្នាំ | អាយុពី៦ឆ្នាំ ដល់ក្រោម ១២ឆ្នាំ | អាយុចាប់១២ ឆ្នាំដល់ក្រោម ១៨ឆ្នាំ |
| | (N=43,646) | (N=1,378,688) | (N=10,000,000) | (N=304,317) | (N=1,897,382) | (N=1,827,348) |
| ចាប់ផ្តើម (2021) | 10 កុម្ភៈ | 10 កុម្ភៈ | 10 កុម្ភៈ | 1 វិច្ឆកា | 17 កញ្ញា | 1 សីហា |
| ដូសទី១ | 43,646 (100%) | 1,393,494 (101.1%) | 10,224,938 (102.2%) | 330,647 (108.7%) | 2,016,416 (106.3%) | 1,822,429 (99.7%) |

[1] តំណាក់កាលចម្លងសម្រាប់ការចាត់ថ្នាក់កម្រិតថ្នាក់ក្រោមជាតិដោយអង្គការសុខភាពពិភពលោកប្រចាំតំបន់ប៉ាស៊ីហ្វិកខាងលិច



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្ន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។

| | | | | | | |
|---|---|---|---|---|---|---|
| ដូសទី២ | 43,646 (100%) | 1,369,756 (99.4%) | 9,880,925 (98.8%) | 256,263 (84.2%) | 1,932,041 (101.8%) | 1,750,344 (95.8%) |
| ដូសទី៣ | 5,423,267 (54.2%) | | | | | 902,354 (49.4%) |
| ដូសទី៤ | 813,180 (8.1%) | | | | | |

**តារាងទី៤. អត្រានៃហេតុការណ៍កើតមានក្រោយពេលចាក់វ៉ាក់សាំង (AEFI) ក្នុងចំណោម ១០០.០០០ដូស តាមប្រភេទវ៉ាក់សាំងកូវីដ-១៩**

| ប្រភេទវ៉ាក់សាំងកូវីដ-១៩ | Sinovac | Sinopharm | AstraZeneca (Covishield) | Janssen (Ad26.COV2-S) | AstraZeneca (Vaxzevria) | Moderna (Spikevax) | Pfizer BioNTech (Comirnary) | សរុប |
|---|---|---|---|---|---|---|---|---|
| ចំនួនករណី | 98 | 79 | 29 | 4 | 1 | 0 | 0 | 211 |
| ចំនួនដូសសរុបបានចាក់ | 22,063,861 | 7,406,431 | 323,344 | 1,053,151 | 2,332,383 | 249,859 | 383,600 | 33,379,502 |
| អត្រានៃហេតុការណ៍ក្នុងចំណោម ១០០.០០០ដូស | 0.44 | 1.07 | 8.97 | 0.38 | 0.08 | 0 | 0 | 0.62 |

## ឯកសារយើង និងតំណរភ្ជាប់ដែលពាក់ព័ន្ធ

- គេហទំព័រក្រសួងសុខាភិបាល: គេហទំព័រផ្លូវការរបស់ក្រសួងសុខាភិបាល
- របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ដោយក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក: របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់ប្រទេសកម្ពុជា។
- របាយការណ៍ស្តីពីស្ថានភាពថ្នាក់តំបន់:របាយការណ៍ស្តីពីស្ថានភាពជំងឺកូវីដ-១៩ចុងក្រោយបំផុតសម្រាប់អង្គការសុខភាពពិភពលោកតំបន់ប៉ាស៊ីហ្វិកខាងលិច។
- របាយការណ៍ស្តីពីស្ថានភាពថ្នាក់សាកល: របាយការណ៍បច្ចុប្បន្នភាពស្តីពីកូវីដ-១៩ផ្នែកប្រតិបត្តិការ និងអេពីដេមីសាស្ត្ររបស់អង្គការសុខភាពពិភពលោកថ្នាក់សាកល។
- គោលការណែនាំរបស់អង្គការសុខភាពពិភពលោក: គោលការណែនាំសម្រាប់ប្រទេស និងបច្ចេកទេសអំពីកូវីដ-១៩ចុងក្រោយបំផុតរបស់អង្គការសុខភាពពិភពលោក។
- ក្តារព័ត៌មានឌីជីថលស្តីពីកូវីដ-១៩របស់អង្គការសុខភាពពិភពលោក: ទិន្នន័យកូវីដ-១៩កម្រិតតំបន់ និងពិភពលោកចុងក្រោយបំផុត។



**បដិសេធការទទួលខុសត្រូវ:** របាយការណ៍នេះមានព័ត៌មាន និងទិន្នន័យដែលត្រឹមត្រូវល្អក្នុងកំឡុងពេលផ្សព្វផ្សាយប៉ុណ្ណោះ។ ដោយសារការរាតត្បាតនៃជំងឺកូវីដ-១៩ ជាស្ថានការណ៍វិវឌ្ឍន៍ជាប្រចាំ ព័ត៌មាននៅក្នុងឯកសារនេះ អាចនឹងខុសទៅនឹងព័ត៌មានថ្មីៗ។